ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ចន្ទ ៤កើត ខែ ភទ្របទ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧*

*រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា គ.ស. ២០២៣*

# សេចក្តីប្រកាសព័ត៌មាន

## អង្គប្រជុំក្រុមការងារ “ឃ” ផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច
## វេទិការាជរដ្ឋាភិបាលជាមួយវិស័យឯកជន

នាព្រឹកថ្ងៃទី ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០២៣, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជាសហប្រធានក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និង អភិបាលកិច្ច “**ក្រុម ឃ**” នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន រួមជាមួយនឹងលោក អានូដ ដាក (Arnaud Darc) សហប្រធាន “**ក្រុម ឃ**” (ខាងផ្នែកឯកជន) បានដឹកនាំកិច្ចប្រជុំ “**ក្រុម ឃ**” ក្នុងគោលបំណងពិនិត្យ និងពិភាក្សាលើបញ្ហាប្រឈម និងស្តាប់សំណូមពរ ក៏ដូចជាដើម្បីដាក់ចេញវិធានការបន្តដោះស្រាយឱ្យបានសមស្របជូនវិស័យឯកជន វិនិយោគិន និងធុរជននៅក្នុងប្រទេសកម្ពុជា ។

កិច្ចប្រជុំថ្ងៃនេះ មានលក្ខណៈពិសេស គឺជាកិច្ចប្រជុំលើកដំបូងរបស់ “**ក្រុម ឃ**” បន្ទាប់ពីរាជរដ្ឋាភិបាលថ្មី នីតិកាលទី ៧ នៃរដ្ឋសភា ដឹកនាំដោយ**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ចូលកាន់ដំណែងដឹកនាំប្រទេសតាម ***“កម្មវិធីនយោបាយ”*** និង ***“យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១”*** ប្រកបដោយថាមពលជីវភាព និងសមត្ថភាព ។ កិច្ចប្រជុំ ត្រូវបានរៀបចំឡើងក្នុងគោលដៅបន្តជំរុញធុរកិច្ច និងលើកកម្ពស់បរិយាកាសវិនិយោគ ក្នុងខណៈដែលកម្ពុជាសម្រេចបានសមិទ្ធផលជាក់ស្តែងធំៗ និងកំពុងបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍ និងមានការចូលរួមពីសហសេរិកទាំងផ្នែករាជរដ្ឋាភិបាល វិស័យឯកជន ក្រសួង-ស្ថាប័ន និងតំណាងសមាគមពាក់ព័ន្ធ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានអនុញ្ញាតឱ្យមានការពិភាក្សាដោយបើកចំហរវាងភាគីវិស័យឯកជន និង រាជរដ្ឋាភិបាល លើបញ្ហាប្រឈម កង្វល់ និង សំណូមពររបស់វិស័យឯកជន ។ កិច្ចប្រជុំនេះបានពិភាក្សាលើរបៀបវារៈចំនួន ៥ រួមមាន:

**១.** ការអនុវត្តពន្ធអាករលើតម្លៃបន្ថែមលើផលិតផលបារីនាំចូល,

២. ពាណិជ្ជកម្មខុសច្បាប់,

៣. សិទ្ធិផ្តាច់មុខ និងការនាំចូលរថយន្តម៉ូដែលចុងក្រោយស្ថិតក្រោមសិទ្ធិផ្តាច់មុខ,

៤. ការធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់អ្នកជាប់ពន្ធតូច ឬ សហគ្រាសដែលប្តូរទ្រង់ទ្រាយពីរបបម៉ៅការ និង

៥. ការបញ្ចូលភាគហ៊ុននិកបន្ថែមរបស់អ្នកជាប់ពន្ធតូច ឬ សហគ្រាសដែលប្តូរទ្រង់ទ្រាយពីរបបម៉ៅការ ឬ សហគ្រាសឯកបុគ្គល ។ កិច្ចប្រជុំ ក៏បានពិភាក្សាលើការស្នើសុំរៀបចំ "***សៀវភៅ ស***" ដែលជាការចងក្រងនូវកំណត់ហេតុបូកសរុប និងការសម្រេចរបស់អង្គប្រជុំមុនៗផងដែរ ។

ជាលទ្ធផល, អង្គប្រជុំបានដោះស្រាយសំណូមពរ និងធ្វើការបំភ្លឺចំពោះកង្វល់ដែលវិស័យឯកជនបានលើកឡើង និងបានស្នើឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធ រៀបចំដាក់ចេញនូវវិធានការ យន្តការសមស្របសម្រាប់ដោះស្រាយតាមសមត្ថកិច្ច និងភារកិច្ចរៀងខ្លួនៗ ដើម្បីស្វែងរកដំណោះស្រាយសមស្រប យុត្តិធម៌ សំដៅលើកកម្ពស់បរិយាកាសវិនិយោគ និងធុរកិច្ចដែលមានការប្រកួតប្រជែងស្មើភាពគ្នា តម្លាភាព ព្រមទាំងរក្សាបាននូវការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ ដែលមានជាធរមាន ។ កិច្ចប្រជុំ នឹងបន្តពិភាក្សាលើរបៀបវារៈដែលនៅសេសសល់ នៅក្នុងខែ តុលា ឆ្នាំ ២០២៣ បន្តទៀត ។

ជាកិច្ចបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានសំដែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជាសហសេវិកទាំងអស់ ទាំងផ្នែករាជរដ្ឋាភិបាល ទាំងផ្នែកដៃគូវិស័យឯកជន និងបានជូនពរឱ្យទទួលបានជ័យជំនះគ្រប់ភារកិច្ច ។